# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងបរិស្ថាន**

លេខ: ១១០៩.សជណ.ប.ស្ត

ថ្ងៃ...ពុធ ១៥កើត...ខែ...អស្សុជ... ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី...២៤...ខែ...តុលា...ឆ្នាំ២០១៨

## សេចក្តីជូនដំណឹង
## ស្តីពី ការបញ្ឈប់ការកាន់កាប់ដីដោយខុសច្បាប់
## នៅក្នុងឧទ្យានជាតិព្រះសុរាម្រិត-កុសមៈ«គីរីរម្យ»

កន្លងមក ក្រសួងបរិស្ថានពិនិត្យឃើញថា តំបន់មួយចំនួននៅក្នុងឧទ្យានជាតិព្រះសុរាម្រិត-កុសមៈ«គីរីរម្យ» មានចលនាទន្ទ្រានកាន់កាប់ដីរដ្ឋដោយខុសច្បាប់ រួមមាន ការកាប់ទន្ទ្រានកាន់កាប់ ការផ្ទេរ និងទិញលក់ដីដោយខុសច្បាប់ ជាពិសេសច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ទោះបីជាក្រសួងបរិស្ថាន រដ្ឋបាលខេត្តកំពង់ស្ពឺ និងរដ្ឋបាលខេត្តព្រះសីហនុបានខិតខំការពារនិងទប់ស្កាត់យ៉ាងណាក៏ដោយ។

ដើម្បីទប់ស្កាត់សកម្មភាពល្មើសច្បាប់ទាំងនេះ ក្រសួងបរិស្ថានសូមអំពាវនាវ និងដាក់ចេញនូវវិធានការដូចខាងក្រោម៖

- ក្រសួងបរិស្ថានសូមបដិសេធនូវរាល់ឯកសារពាក់ព័ន្ធនឹងការកាន់កាប់ដី ដោយខុសច្បាប់គ្រប់ប្រភេទដូចជា ការកាប់ទន្ទ្រានកាន់កាប់ ការផ្ទេរ និងទិញលក់ដីដោយខុសច្បាប់ នៅក្នុងឧទ្យានជាតិព្រះសុរាម្រិត-កុសមៈ«គីរីរម្យ»
- អ្នកដែលបាននិងកំពុងកាន់កាប់ដីដោយខុសច្បាប់ត្រូវបញ្ឈប់សកម្មភាពទាំងអស់ ( ការឈូសឆាយ និងការសាងសង់សំណង់នានា...)ជាបន្ទាន់ ហើយត្រូវរុះរើសំណង់គ្រប់ប្រភេទ ដោយខ្លួនឯង និងប្រគល់ទីតាំងដីទាំងនោះដោយឥតលក្ខខណ្ឌ មកជូនក្រសួងបរិស្ថានគ្រប់គ្រងវិញ
- ស្ថាប័ននិងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ ត្រូវចាត់វិធានការទប់ស្កាត់ និងបង្ក្រាប ការកាប់គាស់ រុករានដីព្រៃ ឆ្ការ ដុត និងឈូសឆាយដីព្រៃ ព្រមទាំងការសង់ផ្ទះ សង់តូប សង់រោង ដើម្បីយកដីធ្វើជាកម្មសិទ្ធិនៅក្នុងដែនឧទ្យានជាតិព្រះសុរាម្រិត-កុសមៈ«គីរីរម្យ» ដែលជាបទល្មើសធនធានធម្មជាតិ មានចែងក្នុងមាត្រា៦២ និងមាត្រា៦៣ នៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- រដ្ឋបាលមូលដ្ឋាន ជាពិសេសភូមិ ឃុំ និងស្រុក ត្រូវបញ្ឈប់ជាបន្ទាន់នូវការបញ្ជាក់លើលិខិតទិញ-លក់ដីរដ្ឋ ផ្ទេរសិទ្ធិ ឬបញ្ជាក់លើប្លង់បង្ហាញទីតាំងដី នៅក្នុងដែនឧទ្យានជាតិព្រះសុរាម្រិត-កុសមៈ«គីរីរម្យ»។

ទទួលបានសេចក្តីជូនដំណឹងនេះ សូមគ្រប់អង្គភាពមានសមត្ថកិច្ច រដ្ឋបាលមូលដ្ឋាន សាធារណៈ ជនពិសេសប្រជាពលរដ្ឋដែលកំពុងកាន់កាប់ដីដោយខុសច្បាប់ នៅក្នុងតំបន់ឧទ្យានជាតិ ព្រះសុរាម្រិត-កុសមៈ«គីរីរម្យ» ត្រូវចូលរួមសហការអនុវត្ត ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃជូនដំណឹងនេះតទៅ។

**រដ្ឋមន្ត្រី**

**សាយ សំអាល់**

**ចម្លងជូន៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- រដ្ឋបាលខេត្តកំពង់ស្ពឺ និងរដ្ឋបាលខេត្តព្រះសីហនុ
- មន្ទីរបរិស្ថានខេត្តកំពង់ស្ពឺ និងខេត្តព្រះសីហនុ
- មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពង់ស្ពឺ និងខេត្តព្រះសីហនុ
- ឯកសារ-កាលប្បវត្តិ